**ស្ថានទូតអូស្ត្រាលី**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤

# សហគមន៍មកជួបជុំគ្នាក្នុងរាត្រីនៃតន្ត្រីនិងបរិយាបន្ន

កាលពីយប់មិញនេះ លោក Pablo Kang ភារធារីស្ថានទូតអូស្ត្រាលី រួមជាមួយ Mitch Tambo តារាចម្រៀងលំដាប់ពិភពលោកជនជាតិដើមអូស្ត្រាលី និង សាយ តារាចម្រៀង អ្នកនិពន្ធបទចម្រៀង និងសប្បុរសជនបើកការប្រគុំតន្ត្រីសហគមន៍អបអរភាពចម្រុះ និងបរិយាបន្ន។

ការប្រគុំតន្ត្រីនេះបានប្រារព្ធធ្វើឡើងនៅសាលាអន្តរជាតិកាណាដាភ្នំពេញ ដោយប្រមូលផ្តុំទស្សនជនមកពីគ្រប់មជ្ឈដ្ឋាន មកចូលរួមរាត្រីដ៏រស់រវើកនៃវប្បធម៌ តន្ត្រី និងភាពសប្បាយរីករាយ។ ការប្រគុំតន្ត្រីនេះចូលរួមដោយតារាចម្រៀងដ៏អស្ចារ្យពីររូប គឺ Mitch Tambo មកពីប្រទេសអូស្ត្រាលី និង សាយ មកពីប្រទេសកម្ពុជា ដែលតារាចម្រៀងទាំងពីររូបនេះ ត្រូវបានទទួលស្គាល់ដោយសកម្មភាពរបស់ពួកគេក្នុងការជួយដល់សង្គម។

Mitch Tambo ជាអ្នកចម្រៀង និងជាអ្នកនិពន្ធបទចម្រៀងជនជាតិដើមរបស់ប្រទេសអូស្ត្រាលី។ គាត់ជាបុរសជនជាតិ Gamilaraay ដ៏មានមោទនភាព ដែលនាំយកសំឡេង និងភាសាជនជាតិដើមមកលាយចូលជាមួយនឹងចង្វាក់ និងផលិតកម្មសហសម័យ។ គាត់គឺជាឯកអគ្គរដ្ឋទូតរបស់អង្គការយូនីសេហ្វ និងជាបុគ្គលសង្គមដែលមានសមត្ថភាព។ Mitch មានចំណូលចិត្តជាមួយភាពចម្រុះ និងជាអ្នកជំនាញវប្បធម៌ដ៏ល្បី ព្រមទាំងជាអ្នកជម្រុញទឹកចិត្តនៅទូទាំងសាលារៀន និងអង្គការសហគមន៍ក្នុងប្រទេសអូស្ត្រាលីផងដែរ។

ចំណែកសាយវិញ ក្រៅពីការងារថតចម្រៀង គាត់ល្បីល្បាញក្នុងការរត់ពាសពេញប្រទេសកម្ពុជា ដើម្បីរៃអង្គាសប្រាក់សម្រាប់ការស្រាវជ្រាវជំងឺមហារីក។ ក្នុងភាពជាដៃគូជាមួយអង្គការអុកស្វាម គាត់បានចុះ

តាមដងទន្លេមេគង្គ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីបញ្ហាប្រឈមនៃអាកាសធាតុ និងការគ្រប់គ្រងទន្លេសម្រាប់សហគមន៍ទាំងនោះ។

លោក Pablo Kang ភារធារីស្ថានទូតអូស្ត្រាលី បានមានប្រសាសន៍ថា "ការប្រគុំតន្ត្រីនេះមិនមែនគ្រាន់តែជាការកម្សាន្តប៉ុណ្ណោះទេ វាក៏ជាការប្រមូលផ្តុំសហគមន៍របស់យើងដើម្បីមកជួបជុំគ្នាផងដែរ។ ខ្ញុំពិតជារីករាយណាស់ដែលឃើញមនុស្សគ្រប់វ័យ និងគ្រប់មជ្ឈដ្ឋាន មកជួបជុំគ្នាដើម្បីអបអរសហគមន៍យើងតាមរយៈតន្ត្រី និងសិល្បៈ"។

"ភ្ញៀវរបស់យើងមានមកពី ខាងការងារផ្នែកសិទ្ធិមនុស្ស ក៏ដូចជាសិទ្ធិជនជាតិដើមភាគតិច ព្រមទាំងក្រុមតស៊ូមតិផ្នែកស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នា។ មិនថានៅក្នុងប្រទេសអូស្ត្រាលី ប្រទេសកម្ពុជា ឬទូទាំងពិភពលោកទេ បរិយាបន្នពង្រឹងសង្គមដែលយើងចង់រស់នៅ បង្កើតកន្លែងសម្រាប់ទេពកោសល្យ ដោយមិនគិតពីសមត្ថភាពរាងកាយ ពូជសាសន៍ និងភេទ ឡើយ"។

Mitch Tambo រួមជាមួយនឹង Voice of Lele ដែលជាភរិយា និង Sermsah Bin Saad ដែលជាអ្នករាំរបស់គាត់ មកកាន់ទីក្រុងភ្នំពេញ ពីថ្ងៃទី២៣ ដល់ ២៦ ខែមេសា ដើម្បីចែករំលែកតន្ត្រី ចំណង់ចំណូលចិត្ត វប្បធម៌ សិល្បៈ និងរឿងរ៉ាវជនជាតិដើមរបស់គាត់ ជាមួយប្រជាជនកម្ពុជា។ ក្នុងដំណើរទស្សនកិច្ចនេះ លោកបានធ្វើសិក្ខាសាលាមួយចំនួន ជាមួយសិស្សានុសិស្សនៅតាមវិទ្យាល័យ និងសកលវិទ្យាល័យ ព្រមទាំងសហគមន៍សិល្បៈផងដែរ។ Mitch បានផ្សព្វផ្សាយវប្បធម៌ និងសិល្បៈ របស់ជនជាតិដើមអូស្ត្រាលី ដែលជាផ្នែកមួយនៃការតភ្ជាប់ប្រជាជននៃប្រទេសទាំងពីរតាមរយៈតន្ត្រី។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au